ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក
RHB BANK (CAMBODIA) PLC.

**លក្ខខណ្ឌផ្សេងៗសម្រាប់ការបើក ប្រតិបត្តិការទូទៅ និងការបិទគណនីបញ្ញើនៅ ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក (តទៅនេះហៅកាត់ថា "ធនាគារ")**

**១. លក្ខខណ្ឌទូទៅ**

១.១ ការបើក ប្រតិបត្តិការទូទៅ និងការបិទគណនីបញ្ញើត្រូវបានគ្រប់គ្រងដោយ ខ និង លក្ខខណ្ឌ នេះដែលអាចត្រូវបន្ថែម ធ្វើវិសោធនកម្មផ្លាស់ប្តូរ និងកែប្រែម្តងម្កាលតាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ធនាគារដោយជូនដំណឹង ឬមិនបាច់ជូនដំណឹងជាមុន ហើយអ្នកស្នើសុំយល់ព្រមគោរពតាម និងបន្តអនុវត្តតាម ខ និងលក្ខខណ្ឌនេះ ព្រមទាំង ការធ្វើវិសោធនកម្ម ការផ្លាស់ប្តូរ ការកែប្រែ ចំពោះ ខ និងលក្ខខណ្ឌនេះ។

១.២ និយមន័យនៃពាក្យ គណនីបញ្ញើត្រូវរាប់បញ្ចូលនូវគ្រប់ទម្រង់ នៃ គណនីបញ្ញើសំចៃ គណនីចរន្ត និងគណនីបញ្ញើមានកាលកំណត់ដែលកំពុងផ្តល់ជូនដោយធនាគារនាពេលអនាគត។

១.៣ អ្នកស្នើសុំចាំបាច់ត្រូវបំពេញទម្រង់បែបបទសំណុំឯកសារ ព័ត៌មានអតិថិជន (CIF) និងប័ណ្ណចុះហត្ថលេខាគំរូឲ្យបានត្រឹមត្រូវ ហើយត្រូវបញ្ជាក់ថាបានទទួល ខ និងលក្ខខណ្ឌនេះ ដែលគ្រប់គ្រង លើការបើកគណនីនៅចំពោះមុខមន្រ្តីធនាគារដែលមានការអនុញ្ញាត។

១.៤ អ្នកស្នើសុំចាំបាច់ត្រូវធ្វើឯកសារចុះបញ្ជី ឬអត្តសញ្ញាណកម្ម និងឯកសារផ្សេងៗទៀតដែល កំណត់ដោយធនាគារម្តងម្កាលសម្រាប់ការបើកគណនីបញ្ញើ។

១.៥ ការយល់ព្រមទទួលយកពាក្យសុំបើកគណនីលើកដំបូងគឺ ជាឆន្ទានុសិទ្ធិផ្តាច់មុខរបស់ធនាគារ ហើយធនាគារសូមរក្សាសិទ្ធិធ្វើការបដិសេធ ពាក្យសុំដោយមិនចាំបាច់ ប្រាប់ពីមូលហេតុណាមួយឡើយ ហើយសេចក្តីសម្រេចនេះ គឺជាសេចក្តីសម្រេចស្ថាពរ។

១.៦ តាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួន ធនាគារក៏អាចបិទគណនីចោល ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់គណនី អំពីការបិទនេះ ហើយធនាគារពុំមានកាតព្វកិច្ចត្រូវប្រាប់ពីមូលហេតុ នៃការបិទនេះឡើយ។

១.៧ ធនាគាររក្សាសិទ្ធិទាមទារថ្លៃបន្ទុក ថ្លៃសេវា ឬថ្លៃផាកពិន័យដែលត្រូវបង់ជា ប្រាក់ដុល្លារអាមេរិក ឬ ប្រាក់រៀលដែលមានតម្លៃសមមូល។

១.៨ អ្នកស្នើសុំត្រូវមានការឯកភាព ដែលចាំបាច់នានា ប្រសិនបើមាន ពីអាជ្ញាធរកម្ពុជាដែលពាក់ព័ន្ធ ដែលអាចត្រូវស្នើម្តងម្កាល ដើម្បីឲ្យអ្នកសុំអាចធ្វើការបើក រក្សានិង ធ្វើប្រតិបត្តិការគណនីនៅធនាគារ។ ធនាគារអាចស្នើឲ្យអ្នកស្នើសុំផ្តល់ភ័ស្តុតាងអំពី សំណុំឯកសារឯកភាពបែបនោះបានគ្រប់ពេល ប៉ុន្តែ ធនាគារពុំមានកាតព្វកិច្ច ធានាអះអាង និង/ឬ ផ្ទៀងផ្ទាត់ថាការ ឯកភាពនោះ ត្រូវបានផ្តល់ជូនពិតប្រាកដ ឬ យ៉ាងណាឡើយ។

១.៩ ធនាគារសូមរក្សាសិទ្ធិធ្វើការស្នើសុំម្តងម្កាល នូវព័ត៌មាន ឬឯកសារបន្ថែម ដោយអនុលោមតាម ឬយោងតាមច្បាប់កម្ពុជា ជាធរមានស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និង/ឬ ច្បាប់ប្រហាក់ប្រហែលនេះ ដែលមានសុពលភាពនៅប្រទេសកម្ពុជា និង/ឬ នៅប្រទេសម៉ាឡេស៊ី ហើយអ្នកស្នើសុំសន្យាថានឹងផ្តល់ជូនធនាគារភ្លាមៗ នូវព័ត៌មានឬ ឯកសារទាំងនោះនៅពេលដែលមានការស្នើសុំ។

១.១០ អ្នកស្នើសុំសូមសន្យាថានឹងជូនដំណឹងដល់ធនាគារឲ្យបានឆាប់រហ័សបំផុត តាមដែលអាចធ្វើទៅបាន អំពីការផ្លាស់ប្តូរព័ត៌មានមានកំណត់ត្រាពាក់ព័ន្ធផ្សេងៗ ដូចជាការផ្លាស់ប្តូរហត្ថលេខា/ហត្ថលេខី ការផ្លាស់ប្តូរអាសយដ្ឋាន ឬ ព័ត៌មាន ផ្ទាល់ខ្លួន ឬ អាជីវកម្មជាដើម។ ធនាគារមិនទទួលខុសត្រូវចំពោះការបាត់បង់ ដែលកើតឡើងចំពោះម្ចាស់គណនីបណ្តាលមកពីការផ្លាស់ប្តូរព័ត៌មាន ដោយមិនបានជូនដំណឹង ដល់ធនាគារឡើយ។

១.១១ ប្រសិនបើគណនីបញ្ញើមានម្ចាស់ចាប់ពីរនាក់ឡើងទៅ (គណនីរួម) ខ និងលក្ខខណ្ឌនេះត្រូវបានអនុវត្តចំពោះ ម្ចាស់គណនីរួមទាំងអស់ដោយរួមគ្នា និងដោយដាច់ដោយឡែកពីគ្នា។ ម្ចាស់គណនីនីមួយៗត្រូវទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះមុខធនាគារចំពោះទឹកប្រាក់សរុបនៃបំណុលរបស់ម្ចាស់គណនីរួមដទៃទៀតដែលជំពាក់ធនាគារ។ ដោយបង្ហាញភ័ស្តុតាងស្តីពីមរណភាពរបស់ម្ចាស់គណនីរួមណាមួយ មានតែភាគីនៅរស់ប៉ុណ្ណោះដែលត្រូវទទួលស្គាល់ដោយធនាគារថាមានកម្មសិទ្ធិ ឬ ផលប្រយោជន៍នៅក្នុងគណនី ហើយយោងតាម ខ និងលក្ខខណ្ឌនេះ និងការយល់ព្រមជាមុនរបស់ធនាគារ បុគ្គលនោះត្រូវមានសិទ្ធិផ្ទេរគណនីទៅកាន់ឈ្មោះ មួយផ្សេងទៀត ឬ បិទគណនី ឬ ដកប្រាក់ ពីគណនីរួមនេះ ប៉ុន្តែ ជានិច្ចកាលត្រូវទូទាត់ទឹកប្រាក់ទាំងអស់ដែលជំពាក់ធនាគារឲ្យគ្រប់ចំនួន។

១.១២ ការប្រាក់ដែលទទួលបានដោយម្ចាស់គណនីត្រូវទូទាត់ពន្ធកាត់ទុក ឬ ពន្ធអាករផ្សេងៗ ដែលអាចត្រូវបាន កំណត់ម្តងម្កាលដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង អង្គភាពនិយ័តកម្មផ្សេងៗទៀត។

១.១៣ ធនាគារអាចទូទាត់សមតុល្យឥណទានមួយចំនួន ឬទាំងអស់ក្រោមគណនីណាមួយដែលបើកនៅ ធនាគារចំពោះបំណុលណាមួយដែលម្ចាស់គណនី អាចនៅជំពាក់ធនាគារ ដែលដល់ពេលត្រូវសង តែមិនទាន់បានសង។

១.១៤ រាល់ការស្នើសុំ ឬការជូនដំណឹងទៅដល់ម្ចាស់គណនី ដែលត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងផ្ញើទៅកាន់ម្ចាស់គណនី ត្រូវបានចាត់ទុកថា បានទៅដល់ ប្រសិនបើត្រូវបានប្រគល់ដល់ម្ចាស់គណនីដោយផ្ទាល់ ឬ តាមរយៈពេលបី (៣) ថ្ងៃក្រោយពេលផ្ញើតាមប្រៃសនីយ៍ទៅកាន់ អាសយដ្ឋានដែលស្គាល់ចុងក្រោយគេបំផុតរបស់ម្ចាស់គណនី។

១.១៥ ដោយជូនដំណឹង ឬ មិនចាំបាច់ជូនដំណឹងជាមុន ធនាគារអាចផ្លាស់ប្តូរ ខ និងលក្ខខណ្ឌនេះ រួមមានជាអាទិ៍ ផ្លាស់ប្តូរថ្លៃបន្ទុក បញ្ចូលថ្លៃបន្ទុកថ្មីឬបន្ទុកបន្ថែម លក្ខខណ្ឌថ្មី ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរច្បាប់ស្តីពីធនាគារ ឬ ទម្លាប់អនុវត្ត ធនាគារលក្ខខណ្ឌតម្រូវទប់ស្កាត់ ការបន្លំ ការផ្លាស់ប្តូរ លក្ខខណ្ឌតម្រូវបច្ចេកវិទ្យា និង និយ័តកម្ម។

## ២. លក្ខខណ្ឌពិសេសសម្រាប់គណនីបញ្ញើសំចៃ

២.១ ធនាគារតម្រូវឲ្យដាក់ប្រាក់តម្កល់ដំបូងសម្រាប់បើកគណនី លើកដំបូង ហើយតាមឆន្ទានុសិទ្ធិរបស់ធនាគារ សមតុល្យក្នុងកម្រិតអប្បរមាចាំបាច់ត្រូវរក្សា ឲ្យនៅមានគ្រប់ពេល។ ធនាគាររក្សាសិទ្ធិធ្វើការ ផ្លាស់ប្តូរម្តងម្កាលនូវលក្ខខណ្ឌតម្រូវ សម្រាប់ការដាក់ប្រាក់តម្កល់លើកដំបូង និង ទឹកប្រាក់ក្នុងកម្រិតអប្បរមាដែលត្រូវរក្សាឲ្យមាននៅក្នុងគណនីដោយជូនដំណឹង ឬ មិនចាំបាច់ជូនដំណឹងជាមុនឡើយ។

២.២ ការផ្តល់ការប្រាក់ត្រូវបានគណនាដោយយោងតាមសមតុល្យ ដែលមាននៅក្នុងថ្ងៃនីមួយៗ ដោយផ្អែកលើអត្រា និងគោលការណ៍ជាធរមានរបស់ធនាគារ។ ការប្រាក់នឹងត្រូវផ្តល់ជូនក្នុងរយៈពេលប្រាំមួយខែនៅក្នុងគណនីបញ្ញើសំចៃ នៅថ្ងៃចុងក្រោយនៃខែមិថុនានិងខែធ្នូនៃឆ្នាំនីមួយៗ ឬកាលបរិច្ឆេទផ្សេងទៀតដូចដែលបានកំណត់ដោយធនាគារ។

២.៣ ម្ចាស់គណនី ត្រូវបង្ហាញ សៀវភៅប្រាក់បញ្ញើ ប្រសិនបើមាន ពេលដែលធ្វើការដាក់ប្រាក់ ហើយការដាក់ប្រាក់នីមួយៗត្រូវបានអមមកជាមួយនូវបង្កាន់ដៃដាក់ប្រាក់ដែលត្រូវបានបំពេញយ៉ាងត្រឹមត្រូវ។

២.៤ ការដាក់ជាមូលប្បទានប័ត្រ រូបិយណត្តិ ប័ណ្ណប្រៃសណីយ៍ និងប័ណ្ណបើកប្រាក់ លិខិតបង្គាប់បើកប្រាក់ លិខិតសន្យាសងប្រាក់ ក្រដាស ឬ ប័ណ្ណផ្សេងទៀត ដែលអាចនឹងត្រូវបានទទួលយកដោយធនាគារតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

២.៥ ការដកប្រាក់អាច ធ្វើឡើងបានដោយដោយម្ចាស់គណនីផ្ទាល់តែប៉ុណ្ណោះ ដោយត្រូវបង្ហាញ អត្តសញ្ញាណប័ណ្ណ សៀវភៅប្រាក់បញ្ញើ ប្រសិនបើមាន និងទម្រង់បែបបទដកដាក់ប្រាក់ដែលបានបំពេញយ៉ាងត្រឹមត្រូវ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀតដែលអាចត្រូវបានស្នើឡើងដោយធនាគារ ដែលព័ត៌មានលម្អិតនៃឯកសារទាំងនោះ ត្រូវបានផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវដោយធនាគារ។

២.៦ រាល់ការដកប្រាក់ទាំងអស់ត្រូវអាស្រ័យលើភាពអាចមាន នៃ រូបិយប័ណ្ណបែបនោះ និង តាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ធនាគារ ហើយធនាគារ មិនទទួលខុសត្រូវទៅចំពោះម្ចាស់គណនីនៅសាខាណាមួយនៃធនាគារ និង នៅក្នុងរូបិយប័ណ្ណណាមួយដែលត្រូវបានប្តូរតាមអត្រាប្តូរប្រាក់ជាធរមានរបស់ធនាគារ។ ម្ចាស់គណនីនឹងត្រូវផ្តល់សំណងពេញលេញដល់ ធនាគារចំពោះ ការខាតបង់ដែលធនាគារទទួលរង ដោយសារការប្តូរ ការលក់ ឬការទិញនោះ ដែលធនាគារជាអ្នកកំណត់។ ការទូទាត់ប្រាក់បែបនោះត្រូវលើកលែង ធនាគារពីការទទួលខុសត្រូវចំពោះម្ចាស់គណនី។

២.៨ ធនាគារនឹងមិនទទួលខុសត្រូវចំពោះទិន្នន័យ ឬ ទឹកប្រាក់ដែលម្ចាស់គណនីមិនបានទទួលស្គាល់នៅក្នុងសៀវភៅប្រាក់បញ្ញើដែលមាន ហត្ថលេខារបស់បុគ្គលិក ពេញសិទ្ធិ ឬ ធ្វើសុពលកម្ម ដោយម៉ាស៊ីនដកប្រាក់របស់ធនាគារ។ ដូច្នេះម្ចាស់គណនី ពិនិត្យដោយប្រុងប្រយ័ត្ននូវទិន្នន័យដែលមាននៅក្នុងសៀវភៅប្រាក់បញ្ញើមុនពេលចាកចេញពីក្នុងបរិវេណធនាគារ។

២.៨ ការបាត់សៀវភៅប្រាក់បញ្ញើត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ដល់ធនាគារភ្លាម។ ធនាគារមិនទទួលខុសត្រូវសម្រាប់ការបាត់បង់ ឬ ការខូចខាតណាមួយដែលអាចកើតមានឡើងចំពោះ ម្ចាស់គណនី ដោយសារតែការធ្វេសប្រហែសរបស់ម្ចាស់គណនីឡើយ ប្រសិនបើមាន ការដកប្រាក់ដោយក្លែងបន្លំគណនី មុនពេលធនាគារទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការបាត់បង់ សៀវភៅប្រាក់បញ្ញើ។ ធនាគារ នឹងកំណត់ថ្លៃអប្បរមាមួយសម្រាប់ ការចេញសៀវភៅប្រាក់បញ្ញើថ្មី។

២.៩ ប្រសិនបើម្ចាស់គណនី ចង់បិទគណនីបញ្ញើសំចៃ គាត់តម្រូវឲ្យមានវត្តមានដោយផ្ទាល់ ដោយ បង្ហាញសៀវភៅប្រាក់បញ្ញើ ប្រសិនបើមាន និងបំពេញទម្រង់បែបបទ បិទគណនី។ ធនាគារមិនទទួលសេចក្តីណែនាំតាមទូរស័ព្ទ អ៊ីម៉ែល ឬ ការជូនដំណឹងតាមទម្រង់ផ្សេងទៀតឡើយ។

## ៣. លក្ខខណ្ឌពិសេសសម្រាប់គណនីចរន្ត

៣.១ ធនាគារតម្រូវឲ្យដាក់ប្រាក់តម្កល់ដើម្បីបើកគណនីចរន្តលើកដំបូង។ សមតុល្យក្នុងកម្រិតអប្បបរមាមិនតម្រូវឲ្យមាន ជាចាំបាច់ឡើយ ហើយគណនីចរន្តគឺជាគណនីបញ្ញើ ដែលគ្មានការប្រាក់ទេ លើកលែងតែមានបញ្ជាក់ផ្សេងពីនេះ។ ការដាក់ប្រាក់បញ្ញើនីមួយៗ ត្រូវអមដោយបង្កាន់ដៃដាក់ប្រាក់ដែលបានកំណត់។

៣.២ ពាក្យសុំសៀវភៅមូលប្បទានប័ត្រ ធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ក្នុងទម្រង់បែបបទដែលបានកំណត់របស់ធនាគារ។ សៀវភៅមូលប្បទានប័ត្រ នឹងត្រូវផ្ញើទៅកាន់អាសយដ្ឋានប្រៃសណីយ៍ ដែលម្ចាស់គណនីបានផ្តល់ ប្រសិនបើលក្ខខណ្ឌតម្រូវទាំងអស់ដែលគាំទ្រសំណើនោះត្រូវបានបំពេញឬ ប្រមូលដោយផ្ទាល់នៅធនាគារ។ សៀវភៅមូលប្បទានប័ត្រជាបន្តបន្ទាប់ អាចត្រូវបានស្នើសុំតាមរយៈ ក្រដាស់ស្នើសុំដែលមាននៅក្នុងសៀវភៅមូលប្បទានប័ត្រ ក្នុងលក្ខខណ្ឌដែលថាការប្រើប្រាស់គណនីមាន លក្ខណៈគួរជាទីពេញចិត្ត។ ការមកយកសៀវភៅមូលប្បទានប័ត្រដោយតតិយភាគី គឺត្រូវបានអនុញ្ញាត លុះត្រាតែបាន បំពេញទម្រង់បែបបទអនុញ្ញាត យកមូលប្បទានប័ត្រដោយតតិយភាគីជាមុនសិន។

៣.៣ មូលប្បទានប័ត្រមិនអាចដកប្រាក់នៅធនាគារបានទេ លើកលែងតែទម្រង់បែបបទត្រូវបានផ្តល់ និងចុះបញ្ជីសម្រាប់គណនីនីមួយៗ។ មិនគួរប្រើម៉ាស៊ីនសរសេរ អគ្គិសនី/អេឡិចត្រូនិច និងទឹកថ្នាំអាចលុបបាន ដើម្បីសរសេរមូលប្បទានប័ត្រឡើយ។ ធនាគារមិនទទួលខុសត្រូវចំពោះការបាត់បង់ ដែលបណ្តាលមកពីការប្រើប្រាស់ ម៉ាស៊ីនសរសេរ អគ្គិសនី/អេឡិចត្រូនិច និងទឹកថ្នាំអាចលុបបានបែបនេះឡើយ។

៣.៤ ប្រសិនបើម្ចាស់គណនី សរសេរមូលប្បទានប័ត្រច្រើន ឬចេញសេចក្តីណែនាំច្រើនដើម្បី ទូទាត់ប្រាក់លើគណនីរបស់ខ្លួន ចំនួនទឹកប្រាក់ សរុបនៃមូលប្បទានប័ត្រ ឬសេចក្តីនៃនាំឲ្យបើកប្រាក់ ដែលលើសសមតុល្យឥណទានដែលមាន ឬការរៀបចំជាមុនណាមួយដែលធ្វើឡើង ជាមួយធនាគារនោះយោងតាមឆន្ទានុសិទ្ធិផ្តាច់មុខ របស់ខ្លួនហើយដោយមិនចាំបាច់គោរពតាមកាលបរិច្ឆេទដែល សរសេរនៅ លើមូលប្បទានប័ត្រ ឬកាលបរិច្ឆេទនៃសេចក្តីណែនាំនោះ ពេលវេលាដែលបានទទួល ឬចំនួន ទឹកប្រាក់ដែលមានកំណត់នៅលើមូលប្បទានប័ត្រ ធនាគារមានសិទ្ធិកំណត់ថាតើមូលប្បទានប័ត្រ ឬសេចក្តីណែនាំដែលត្រូវទូទាត់ឬអនុវត្ត។

៣.៥ ការជូនដំណឹងអំពីបំណងបញ្ឈប់ការទូទាត់ប្រាក់តាមមូលប្បទានប័ត្រ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយការជូនដំណឹងនេះ ត្រូវបញ្ជូននូវព័ត៌មានលម្អិតដូចតទៅៈ លេខមូលប្បទានប័ត្រ លេខគណនីចំនួនប្រាក់ឈ្មោះអ្នកទទួលនិង កាលបរិច្ឆេទ។ ធនាគារនឹងកត់ត្រា តែសេចក្តីបង្គាប់ឲ្យលុយចោលការទូទាត់ប្រាក់តាម មូលប្បទានប័ត្រប៉ុណ្ណោះនៅពេលទទួលបាន លិខិតជូនដំណឹងពីម្ចាស់គណនី។ ធនាគារមិនទទួលខុសត្រូវ ចំពោះការបាត់បង់ដែលបណ្តាលមកពីការធ្វេសប្រហែស ឬការមិនទទួលបានលិខិតជូនដំណឹងឡើយ។ សេចក្តីណែនាំឲ្យបញ្ឈប់ ការទូទាត់ប្រាក់តាមមូលប្បទានប័ត្រ ដែលផ្ញើមកដោយផ្ទាល់មាត់ ឬតាមទូរស័ព្ទ ឬ ទូរលេខមិនអាចទទួលស្គាល់បានដោយធនាគារឡើយ លើកលែងតែសេចក្តីណែនាំឲ្យបញ្ឈប់ការទូទាត់ប្រាក់ តាមមូលប្បទានប័ត្រនោះមានអមមកតាមក្រោយភ្លាមៗ នូវលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សររបស់ម្ចាស់គណនី។

៣.៦ ធនាគារ មិនទទួលខុសត្រូវ ទោះក្នុងកាលៈទេសៈណាក៏ដោយ ចំពោះការបាត់បង់ដែលម្ចាស់គណនី ទទួលរងដោយសារសេចក្តីណែនាំផ្ទាល់មាត់ តាមទូរស័ព្ទ ឬទូរលេខឲ្យបញ្ឈប់ការទូទាត់ប្រាក់តាមមូលប្បទានប័ត្រឡើយ។ ក្នុងករណីដែលមូលប្បទានប័ត្រ បានបដិសេធមិនទូទាត់ប្រាក់ឲ្យដោយធនាគារ ធនាគារអាច (ប៉ុន្តែមិនមែនជាកាតព្វកិច្ច) ប្រគល់មូលប្បទានប័ត្រ ឲ្យអ្នកមូលប្បទានប័ត្រវិញ ដោយបញ្ជាក់ ឬមិនបញ្ជាក់អំពីមូលហេតុ ។ ធនាគារមិនទទួលខុសត្រូវ ចំពោះអ្នកចេញ មូលប្បទានប័ត្រ អត្ថគាហក ឬ តតិយភាគីណាមួយចំពោះ ការបដិសេធទូទាត់ប្រាក់តាមមូលប្បទានប័ត្រឡើយ ទោះបីជាមូលប្បទានប័ត្រនោះអាចត្រូវបានទទួលស្គាល់ក៏ដោយ ប្រសិនបើធនាគារកាន់ជំហររបស់ខ្លួនដោយសុចរិតនោះ។

៣.៧ របាយការណ៍គណនីនឹងត្រូវផ្តល់ជារៀងរាល់ខែ ។ ប្រសិនបើធនាគារមិនបានទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរណាមួយអំពី កំហុសឆ្គង ឬភាពមិនស៊ីសង្វាក់គ្នាទាក់ទងនឹងទិន្នន័យឥណពន្ធ ឬទិន្នន័យឥណទាននៅក្នុងរបាយការណ៍ ក្នុងរយៈពេល ១៤ថ្ងៃ ចាប់ពីថ្ងៃចុងក្រោយនៃសពុលភាពរបស់របាយការណ៍ទនោះ ម្ចាស់គណនីត្រូវចាត់ទុកថាបានយល់ព្រម តាមទិន្នន័យទាំងនោះដែលបាន ធ្វើបច្ចុប្បន្នភាពរហូតមកដល់កាលបរិច្ឆេទចុងក្រោយ នៃការបញ្ចូលទិន្នន័យ នៅក្នុងរបាយការណ៍ថា ត្រឹមត្រូវ ភ្ជាប់កាតព្វកិច្ច និងពេញលេញ។

៣.៨ ធនាគារសូមរក្សាសិទ្ធិកំណត់ថ្លៃសេវារៀងរាល់ប្រាំមួយខែម្តង ព្រមទាំងទាមទារថ្លៃសម្រាប់ ការចេញសៀវភៅមូលប្បទានប័ត្រ និង ការបិទគណនីដែរ។ ការបិទគណនីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ហើយសេចក្តីណែនាំដែលផ្ញើមកដោយផ្ទាល់មាត់ ឬតាមទូរស័ព្ទ ទូរពុម្ព ឬទូរលេខ អាចនឹងមិនទទួលយកដោយធនាគារឡើយ។

៣.៩ មូលប្បទានប័ត្រទាំងអស់គឺនៅតែជាទ្រព្យសម្បត្តិ របស់ធនាគារដដែលហើយក្រោយពេល បិទគណនីចរន្ត មូលប្បទានប័ត្រដែលមិនទាន់បានប្រើទាំងអស់ត្រូវប្រគល់ ជូនធនាគារវិញជាបន្ទាន់។

**៤. លក្ខខណ្ឌពិសេសសម្រាប់បញ្ញើមានកាលកំណត់**

៤.១ ធនាគារតម្រូវឲ្យដាក់ប្រាក់តម្កល់ក្នុងកម្រិតអប្បបរមាមួយ ហើយរក្សាសិទ្ធិធ្វើ ការផ្លាស់ប្តូរ ចំនួនទឹកប្រាក់តម្កល់អប្បបរមានោះ ម្តងម្កាលតាម ឆន្ទានុសិទ្ធិ ផ្តាច់មុខរបស់ខ្លួន ដោយជូនដំណឹង ឬមិនចាំបាច់ជូនដំណឹងជាមុនឡើយ។

៤.២ អត្រាការប្រាក់នៃបញ្ញើមានកាលកំណត់ គឺអត្រាដែលត្រូវបានបោះផ្សាយដោយធនាគារ ហើយធនាគាររក្សាសិទ្ធិធ្វើ ការផ្លាស់ប្តូរអត្រាការប្រាក់ ម្តងម្កាលតាម ឆន្ទានុសិទ្ធិ ផ្តាច់មុខរបស់ខ្លួន ដោយជូនដំណឹង ឬមិនចាំបាច់ជូនដំណឹងជាមុនឡើយ។

៤.៣ លិខិតបញ្ជាក់បញ្ញើមានកាលកំណត់ នឹងត្រូវផ្តល់ជាភស្តុតាងនៃការដាក់ប្រាក់នៅបញ្ជរប្រតិបត្តិការ ។ ការបាត់លិខិតបញ្ជាក់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់ធនាគារ ហើយធនាគារមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតដែលទទួលរង ឬកើតឡើងចំពោះម្ចាស់គណនី ដោយសារការធ្វេសប្រហែសរបស់ម្ចាស់គណនី ឡើយ ប្រសិនបើមានការដកប្រាក់ដោយក្លែងបន្លំ ពីគណនីមុនពេលធនាគារដឹងអំពីការបាត់លិខិតបញ្ជាក់នោះ។

៤.៤ លិខិតបញ្ជាក់បញ្ញើមានកាលកំណត់ត្រូវប្រគល់ឲ្យធនាគារវិញ ដើម្បីធ្វើបច្ចុប្បន្នភាពបន្ត ឬដកប្រាក់។ ម្ចាស់បញ្ញើត្រូវបានស្នើឲ្យធ្វើបដិលេខលើខ្នងលិខិតបញ្ជាក់សម្រាប់ការដកប្រាក់។ វាអាចអនុវត្តទៅបានតែចំពោះការដាក់ប្រាក់បញ្ញើមានកាលកំណត់ និងការដកប្រាក់បញ្ញើមានកាលកំណត់ តាមបញ្ជរប្រតិបត្តិការ ។

៤.៥ លិខិតបញ្ជាក់បញ្ញើមានកាលកំណត់ នឹងត្រូវចាត់ទុកជាមោឃៈ ឬអស់ប្រសិទ្ធភាពចាប់ពីថ្ងៃដែលម្ចាស់គណនី ធ្វើការដកប្រាក់បញ្ញើមានកាលកំណត់តាមរយៈកម្មវិធីធនាគារចល័តតាមទូរស័ព្ទ (goWave by RHB) ។

៤.៦ ការដកប្រាក់មួយផ្នែកមុនកាលកំណត់ នឹងចាត់ទុកថាជាការដកប្រាក់មុនកាលកំណត់។

៤.៧ សម្រាប់ការដកប្រាក់មុនតណាប្រតិទាន គ្មានការបង់ប្រាក់ឡើយ។ ប៉ុន្តែធនាគាររក្សាសិទ្ធិបង់ការប្រាក់ដែលបានកំណត់ សម្រាប់បញ្ញើណាដែលត្រូវបានផ្ញើនឹងធនាគារអស់រយៈពេលច្រើនជាងបីខែ ។

៤.៨ ការប្រាក់ដែលត្រូវបង់ត្រូវដកពន្ធកាត់ទុកដែលត្រូវបាន កំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និង/ឬអង្គភាពនិយ័តកម្មផ្សេងទៀត ។

៤.៩ ការបិទគណនីបញ្ញើមានកាលកំណត់ត្រូវធ្វើឡើង ដោយបង្ហាញលិខិតបញ្ជាក់បញ្ញើមានកាលកំណត់នៅបញ្ជរប្រតិបត្តិការ និងពុំចាំបាច់មាន សេចក្តីណែនាំអំពីកាលបរិច្ឆេទកំណត់ឡើយ។ បញ្ញើមានកាលកំណត់ទាំងអស់ ត្រូវកើនឡើងដោយស្វ័យប្រវត្តិដោយផ្អែកលើអត្រាការប្រាក់ជាធរមានរបស់ធនាគារ។

៤.១០ ធនាគាររក្សាសិទ្ធិបន្ថែមលក្ខខណ្ឌថ្មី ឬកែប្រែ ឬផ្លាស់ប្តូរលក្ខខណ្ឌដែលមានស្រាប់ដូចមាន ចែងនៅខាងលើម្តងម្កាល ដោយមិនចាំបាច់ជូនដំណឹងជាមុនឡើយ។ លក្ខខណ្ឌថ្មី កែប្រែ និងផ្លាស់ប្តូរទាំងនេះ ត្រូវបានភ្ជាប់កាតព្វកិច្ចភ្លាមៗលើម្ចាស់បញ្ញើ ។

**៥. សំណង**

៥.១ ម្ចាស់គណនីយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយឥតកែប្រែក្នុងការផ្តល់សំណងដល់ធនាគារ និងធានាថា ធនាគារនឹងត្រូវបានសង ចំពោះការតវ៉ា ការទាមទារ បណ្តឹងបំណុល ការខូចខាត សោហ៊ុយ ការខាតបង់ និងការចំណាយគ្រប់ប្រភេទដែលធនាគារអាច ទទួលរងទោះជាដោយប្រការណាមួយក៏ដោយទាក់ទងនឹងឥណទាន ឬសេវាកម្ម ធនាគារ ឬកម្ចី ការផ្តល់សេវាធនាគារដល់ម្ចាស់គណនី មូលប្បទានប័ត្រ ឬឯកសារផ្សេងទៀត របស់ឬដើម្បីម្ចាស់គណនី ឬគណនីណាមួយរបស់ ម្ចាស់គណនី ("ការទទួលខុសត្រូវរបស់ធនាគារ"។ ហើយដោយមិនកំហិតត្រឹមប្រការទាំងឡាយដែលបានរៀបរាប់ខាងលើ យល់ព្រមបង់ឲ្យធនាគារតាមការស្នើសុំនូវរាល់ទឹកប្រាក់ ដែលអាចត្រូវបានទាមទារពីធនាគារ ឬដែលធនាគារអាចបង់ ឬត្រូវបង់ក្រោម ឬដោយសារ ឬទាក់ទងនឹងការទទួលខុសត្រូវរបស់ធនាគារ។

៥.២ ធនាគារអាចបង់ភ្លាមៗនូវទឹកប្រាក់ណាមួយ និងទាំងអស់ដែលត្រូវបានទាមទារពីធនាគារ ឬដែលធនាគារអាចប្រែជាមានបន្ទុកត្រូវ បង់ក្រោម ឬទាក់ទងនឹងការទទួល ខុសត្រូវ របស់ធនាគារ ដោយមិនពាក់ព័ន្ធនឹង ឬមានការអនុញ្ញាតបន្ថែមពីម្ចាស់គណនី និងដោយមិនចាំបាច់សួរនាំថាតើ ការទាមទារពីធនាគារត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវដែរ ឬទេ ទោះបីជាម្ចាស់គណនីមិនយល់ស្របនឹងសុពលភាពនៃការទាមទារនោះក៏ដោយ ហើយម្ចាស់គណនីត្រូវយល់ព្រមទទួលយកការទាមទារពីធនាគារ និងការទូទាត់ប្រាកណាមួយដែល ធនាគារធ្វើឡើងពាក់ព័ន្ធនឹងម្ចាស់គណនី។ ទឹកប្រាក់ដែលបង់ដោយធនាគារ ត្រូវដកពីគណនី របស់ ម្ចាស់គណនីបញ្ញើនៅធនាគារ។

៥.៣ ម្ចាស់គណនីអនុញ្ញាត ឲ្យធនាគារបញ្ចេញព័ត៌មានទាក់ទង នឹងម្ចាស់គណនី ចុះកិច្ចការហិរញ្ញវត្ថុ ឬគណនីរបស់ម្ចាស់គណនីបានគ្រប់ពេល ដល់ក្រុមហ៊ុន ឬសាខារបស់ធនាគារ ទោះមានទីតាំស្ថិតនៅកន្លែងណាក៏ដោយ ដល់ភ្នាក់ងារ បុគ្គលិក អ្នកចុះកិច្ចសន្យាឯករាជ្យ និង/ឬសមាជិក ព្រមទាំងប្រសិនបើ និងនៅពេលត្រូវស្នើឲ្យធ្វើដូច្នោះ ដោយអាជ្ញាធរកម្ពុជា ឬអាជ្ញាធរនិយ័តកម្មផ្សេងទៀត។ ម្ចាស់គណនីយល់ព្រមអនុញ្ញាតឲ្យធនាគារបញ្ចេញព័ត៌មាន ដែលរួមមានជាអាទិ៍ ស្ថានភាពគណនីរបស់ម្ចាស់

គណនីដែលផ្ញើនៅធនាគារ ដែលអាចត្រូវបានតម្រូវដោយធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរនិយ័តកម្មផ្សេងទៀតដែលធនាគារត្រូវគោរពតាមម្តងម្កាល។ ការធ្វើបែបនេះ ធនាគារត្រូវរួចផុតពីទំនួលខុសត្រូវ ឬកាតព្វកិច្ចគ្រប់បែបយ៉ាងទាំងអស់។

## ៦. ផ្សេងៗ

៦.១ សិទ្ធិរបស់ធនាគារក្រោម ខ និងលក្ខខណ្ឌនេះ ត្រូវបន្ថែមលើសិទ្ធិផ្សេងទៀតទាំងអស់ដែលធនាគារមាន។ ប្រសិនបើ ខ និងលក្ខខណ្ឌណាមួយ ឬលក្ខខណ្ឌនៃ កិច្ចព្រមព្រៀងណាមួយម្ចាស់គណនីមានលក្ខណៈ មិនស្របច្បាប់ ឬអនុវត្តបាននោះ តាមការជ្រើសរើសរបស់ធនាគារ ខ និងលក្ខខណ្ឌទាំងនោះអាចដកចេញពី ខ និងលក្ខខណ្ឌនេះដោយ មិនប៉ះពាល់ដល់ ខ និងលក្ខខណ្ឌផ្សេងទៀតឡើយ។

៦.២ ធនាគារអាចរក្សា ទុកជាវត្ថុធានាសម្រាប់បំណុលដែលជំពាក់ធនាគារនូវទ្រព្យសម្បត្តិ ឬប្រាក់ ឬទ្រព្យសកម្មទាំងអស់របស់ម្ចាស់គណនី ឬដែលដាក់ផ្ញើដោយម្ចាស់គណនីនៅក្នុងការកាន់កាប់ ឬថែរក្សារបស់ធនាគារ ដើម្បីរក្សាសុវត្ថិភាព ឬសម្រាប់គោលបំណងផ្សេងពីនេះ។ ធនាគារមិនទទួលខុសត្រូវ ចំពោះការបាត់បង់ដែលម្ចាស់គណនីទទួលរង ទាក់ទងនឹងទ្រព្យសម្បត្តិ ឯកសារ ឬទ្រព្យសកម្ម ផ្សេងទៀត ដែលធនាគារថែរក្សា ដើម្បីរក្សាសុវត្ថិភាព ឬសម្រាប់គោលបំណងផ្សេងពីនេះឡើយ។

៦.៣ ការមិនអនុវត្តឬការខកខាន ឬការយឺតយ៉ាវណាមួយរបស់ធនាគារក្នុងការអនុវត្តសិទ្ធិ អំណាច ឬឧបាស្រ័យ ឬការអនុវត្តដោយផ្នែក នៃសិទ្ធិអំណាច ឬឧបាស្រ័យនោះ មិនត្រូវចាត់ទុកថា ជាការបោះបង់សិទ្ធិ អំណាច ឬឧបាស្រ័យនោះឡើយ ហើយមិនត្រូវ រារាំងដល់ ការអនុវត្តនូវសិទ្ធិ អំណាច ឬឧបាស្រ័យនោះឡើយ។ សិទ្ធិអំណាច និងឧបាស្រ័យ របស់ធនាគារ ត្រូវបន្តប្រកបដោយអានុភាព និង ប្រសិទ្ធភាពពេញលេញ រហូតដល់សិទ្ធិនោះ ត្រូវបោះបង់ចោល យ៉ាងជាក់លាក់ដោយឯកសារជាលាយលក្ខណ៍អក្សរ ដែលចុះហត្ថលេខាដោយធនាគារ។

៦.៤ ទាក់ទងនឹងបំណុលរបស់ខ្លួនដែលកើនឡើងម្តងម្កាល ចំពោះធនាគារ ម្ចាស់គណនីត្រូវលះបង់ ដោយមិនអាចកែប្រែបាននូវអភ័យឯកសិទ្ធិ (អធិបតេយ្យ ឬអ្វីផ្សេងទៀត) ដែលខ្លួន ឬទ្រព្យសម្បត្តិ ឬទ្រព្យសកម្មណាមួយរបស់ខ្លួនអាចមានសិទ្ធិបាន យោងតាមច្បាប់ ចាប់ពីពេលចូលជាធរមានឬ ដំណើរការក្តីផ្លូវច្បាប់ផ្សេងទៀត ឬសាលក្រមតុលាការ ឬសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលណាមួយ។

៦៥ ប្រសិនបើការទូទាត់ប្រាក់ដែលត្រូវបង់ឲ្យ ធនាគារដោយម្ចាស់គណនីត្រូវកាត់ទុក ឬកាត់ចេញ ម្ចាស់គណនីត្រូវបង់ឲ្យធនាគារ នូវប្រាក់បន្ថែមនោះ តាមការចាំបាច់ដើម្បីធានាថា ធនាគារបានទទួល មានសិទ្ធិរក្សាទុក និងដោយគ្មានទំនួលខុសត្រូវបន្ថែមពី សំណាក់ធនាគារនូវទឹកប្រាក់សុទ្ធ ដែលស្មើ នឹង ទឹកប្រាក់ដែលគួរត្រូវបានជំពាក់ដោយម្ចាស់គណនី គ្មានការកាត់ទុក ឬកាត់ចេញនោះ ត្រូវបានធ្វើឡើយ។

៦.៦ បំណុលរបស់ម្ចាស់គណនីដែល ជំពាក់ធនាគារនឹងមិនរងផលប៉ះពាល់ដោយការផ្លាស់ប្តូរណាមួយ នៃលក្ខន្តិកៈ ឬឋានៈផ្លូវច្បាប់របស់ធនាគារឡើយ ហើយនឹងភ្ជាប់កាតព្វកិច្ចលើអ្នកស្នងមរតកទាំងអស់ ឬអ្នកតំណាងនៃម្ចាស់គណនី។

៦.៧ ម្ចាស់គណនីមិនត្រូវធ្វើអនុប្បទាន ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចណាមួយក្រោម ឬទាក់ទងនឹងគណនី ឬកិច្ចព្រមព្រៀងផ្សេងទៀត ឬចម្លងការដែលចុះរវាងម្ចាស់គណនី និងធនាគារ ឲ្យភាគីណាមួយ ដោយគ្មានការយល់ព្រមលាយលក្ខណ៍អក្សរជាមុន ពីធនាគារឡើយ ហើយធនាគារមានឆន្ទានុសិទ្ធិដកហូតលិខិតយល់ព្រមដោយមិនចាំបាច់បញ្ជាក់អំពីមូលហេតុ នៃការបដិសេធនេះឡើយ។

៦៨ ក្នុងកម្រិតដែលសំណៅជាភាសាខ្មែរនៃឯកសារណាមួយ រួមទាំង ខ និងលក្ខខណ្ឌនេះ ពុំមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយសំណៅជា ភាសាអង់គ្លេស លក្ខខណ្ឌនៃសំណៅជាភាសាអង់គ្លេសត្រូវយកធ្វើជាគោល។

៦.៩ ខ និង លក្ខខណ្ឌនេះត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសកម្ពុជា។ ម្ចាស់គណនីយល់ព្រមដោយឥតកែប្រែថា ក្នុងករណីមានវិវាទកើតឡើងទាក់ទងនឹង ខ និង លក្ខខណ្ឌនេះ ឬកិច្ចព្រមព្រៀងផ្សេងទៀតរវាងធនាគារ និងម្ចាស់គណនី ឬបញ្ហាផ្នែកហិរញ្ញវត្ថុ ឬអាជីវកម្ម ផ្សេងទៀតរវាងធនាគារ និងម្ចាស់គណនីតាមការជ្រើសរើសផ្តាច់មុខ របស់ធនាគារ វិវាទនោះត្រូវបញ្ជូន និងដោះស្រាយដោយតុលាការ នៃប្រទេសកម្ពុជា។ សេចក្តីបង្គាប់ ឬសេចក្តីសម្រេចរបស់តុលាការគឺជាសេចក្តីបង្គាប់ ឬសេចក្តីសម្រេចដែលភ្ជាប់កាតព្វកិច្ច និងស្ថាពរ។ ថ្លៃចំណាយគឺជាបន្ទុករបស់ម្ចាស់គណនីដែលកំណត់ដោយតុលាការ។

៦.១០ ម្ចាស់គណនីត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនៃព័ត៌មានដែលបានផ្តល់ឲ្យធនាគារ។ ធនាគារមិនទទួលខុសត្រូវចំពោះ ផលវិបាកដែលបណ្តាលមកពីព័ត៌មានក្លែងបន្លំដែលម្ចាស់គណនីបានផ្តល់ឡើយ។

## ៧. ពាក្យស្នើសុំប្រើប័ណ្ណ ATM និងលក្ខខណ្ឌ

ខាងក្រោមនេះគឺជា ខ និងលក្ខខណ្ឌដែលគ្រប់គ្រងលើការប្រើប្រាស់ប័ណ្ណ ATM របស់ធនាគារ អ អេច ប៊ី ("ប័ណ្ណ") ដែលចេញឲ្យប្រើដោយធនាគារ **អ អេច ប៊ី (ខេមបូឌា)** ម.ក ("ធនាគារ") ដល់ម្ចាស់ប័ណ្ណដែលអាចប្រើ ដើម្បីធ្វើចម្លងការធនាគារដែលមានការ អនុញ្ញាតតាមរយៈម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ("ATM")។

៧.១ អាយុតិចបំផុតដែលអាចមានសិទ្ធិស្នើសុំប្រើប័ណ្ណ គឺ ១៨ឆ្នាំ។ ប័ណ្ណនេះត្រូវផ្តល់ឲ្យតែម្ចាស់ គណនីបញ្ញើសំចៃ និងគណនីចរន្ត ដែលជានិវាសនជន ឬអនិវាសនជនប៉ុណ្ណោះ។ ចំពោះគណនីកុមារ ប័ណ្ណត្រូវធ្វើឡើង ដោយឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ ។ ក្នុងករណីម្ចាស់គណនីរួម ការចេញប័ណ្ណនឹងត្រូវអនុញ្ញាត តែនៅក្នុងលក្ខខណ្ឌដែល "ភាគីម្ខាង" ចុះហត្ថលេខាប៉ុណ្ណោះ។

៧.២ ប័ណ្ណនឹងនៅតែជាទ្រព្យសម្បត្តិរបស់ធនាគារជានិច្ចគ្រប់ពេល និងត្រូវប្រគល់ឲ្យធនាគារវិញ តាមការស្នើសុំ ប្រសិនបើធនាគារ តាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួន យល់ឃើញថា ក) ប័ណ្ណត្រូវបានប្រើប្រាស់ ដើម្បីគោលបំណងមិនស្របច្បាប់ ខ) ធនាគារសម្រេចចិត្តជំនួសប័ណ្ណនោះដោយប្រភេទប័ណ្ណដូចគ្នា ឬប្រភេទប័ណ្ណផ្សេងទៀត គ) ម្ចាស់ប័ណ្ណឈប់ប្រើសេវាប័ណ្ណដោយស្ម័គ្រចិត្ត ឃ) ឬមូលហេតុផ្សេងទៀតដែលមិនបានត្រូវរៀបរាប់ច្បាស់លាស់នៅក្នុង ខ និងលក្ខខណ្ឌនេះ។

៧.៣ ប័ណ្ណមិនអាចផ្ទេរ និងមិនត្រូវប្រើដោយភាគីណាមួយក្រៅពីម្ចាស់ប័ណ្ណ ឬប្រើធ្វើជាវត្ថុធានា ឬបញ្ចាំបានឡើយ ទោះជាតាមរបៀបណាក៏ដោយ។ តាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួន ធនាគាររក្សាសិទ្ធិដកហូតប័ណ្ណនិង/ឬ សេវាដែលត្រូវបានផ្តល់បាននៅគ្រប់ពេល ដោយមិនចាំបាច់បញ្ជាក់អំពីមូលហេតុ និង ជូនដំណឹងជាមុនឡើយ។

៧.៤ យោងតាមបញ្ញត្តិនៃវាក្យខ័ណ្ឌទី ៧ ម្ចាស់ប័ណ្ណត្រូវទទួលខុសត្រូវទាំងស្រុងចំពោះរាល់ចម្លងការ ដែលធ្វើឡើងតាមរយៈប័ណ្ណទោះបីមាន ឬគ្មានការអនុញ្ញាតពី សំណាក់ម្ចាស់ប័ណ្ណក៏ដោយ។

៧.៥ គណនីរបស់ម្ចាស់ប័ណ្ណ ត្រូវកត់ត្រាជាឥណពន្ធសម្រាប់ការដកប្រាក់ ការផ្ទេរប្រាក់ (ទោះជាទៅ គណនីរបស់ខ្លួនផ្ទាល់ ឬទៅគណនីរបស់តតិយភាគីក៏ដោយ) និង/ឬ ចម្លងការផ្សេងទៀតដែលធ្វើឡើងដោយការប្រើប្រាស់ប័ណ្ណ។ ម្ចាស់ប័ណ្ណត្រូវទទួលខុសត្រូវ ក្នុងការរក្សាចំនួនទឹកប្រាក់ឲ្យបានគ្រប់គ្រាន់នៅក្នុងគណនី ដើម្បីបំពេញ កាតព្វកិច្ចទាំងនេះ។

៧.៦ លេខកូដសម្ងាត់ ("PIN") ដែលបានចេញជូនម្ចាស់ប័ណ្ណ និងលេខនៃលេខកូដសម្ងាត់ដែលត្រូវ បានផ្លាស់ប្តូរដោយម្ចាស់ប័ណ្ណ ត្រូវរក្សាជាការសម្ងាត់បំផុត។ ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ម្ចាស់ប័ណ្ណមិនត្រូវប្រាប់លេខកូដ PIN ឲ្យតតិយភាគីណាមួយដឹងឡើយ ទោះជាដោយស្ម័គ្រចិត្ត ឬផ្សេងពីនេះក៏ដោយ។ ម្ចាស់ប័ណ្ណមិនត្រូវទុកកំណត់ត្រាជាលាយលក្ខណអក្សរនៃលេខកូដ PIN នៅកន្លែង ឬក្នុងរបៀបដែលឲ្យតតិយភាគីប្រើប្រាស់ប័ណ្ណឡើយ។

៧.៧ ការបាត់ ឬត្រូវចោរលួចប័ណ្ណ ត្រូវរាយការណ៍ជាបន្ទាន់ដល់ធនាគារ និងបញ្ជាក់ជាលាយលក្ខណអក្សរបានឆាប់រហ័សបំផុតតាមដែលអាចធ្វើបាន។ ម្ចាស់ប័ណ្ណត្រូវ ទទួលខុសត្រូវទាក់ទងនឹងការណែនាំអំពី ចម្លងការដែលធ្វើឡើងមុនពេលធនាគារទទួលបានការជូនដំណឹងជាលាយលក្ខណអក្សរអំពីការបាត់ ឬត្រូវចោរលួចនោះ។ ធនាគារត្រូវចុះជាឥណពន្ធ លើគណនីរបស់ម្ចាស់ប័ណ្ណ ចំពោះថ្លៃចំណាយដែលកើតឡើង ក្នុងការចេញប័ណ្ណថ្មីឲ្យម្ចាស់ប័ណ្ណ។

៧.៨ ក្នុងករណីប័ណ្ណមានការខូចខាត ម្ចាស់ប័ណ្ណត្រូវជូនដំណឹងដល់ធនាគារជាបន្ទាន់ ហើយសំណើប័ណ្ណថ្មីក្នុងកម្រិតមួយដែលកំណត់ដោយធនាគារ។

៧.៩ នៅពេលដែលម្ចាស់ប័ណ្ណមានបំណងដកប្រាក់ជាប្រាក់រៀល ដែលស្មើនឹងទឹកប្រាក់ដែលមាន នៅក្នុងឥណទានរបស់គណនីជាប្រាក់ដុល្លារអាមេរិករបស់ខ្លួន ឬបញ្ច្រាសមកវិញនោះត្រូវអនុវត្តតាម អាត្រាប្តូរប្រាក់ដុល្លារ អាមេរិក/រៀល ប្រចាំថ្ងៃរបស់ធនាគារនៅពេលមានចម្លងការកើតឡើង។

៧.១០ ធនាគារមិនទទួលខុសត្រូវចំពោះការខកខានក្នុងការផ្តល់សេវាណាមួយ ឬក្នុងការបំពេញ កាតព្វកិច្ចណាមួយនៅក្នុង ខ និងលក្ខខណ្ឌនេះដែលពាក់ព័ន្ធ នឹងប័ណ្ណនៅពេលដែលការខកខាននោះកើតឡើងដោយការ ដំណើរការមិនប្រក្រតីរបស់ម៉ាស៊ីន ATM ឬការខូចខាតប័ណ្ណ ឬដោយការទំនាស់ដែលធនាគារអាចមានជាមួយម្ចាស់ប័ណ្ណឡើយ។ ធនាគារមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតឡើយ ទោះជាកើតឡើងដោយសារ ឬទាក់ទងនឹង ការប្រើប្រាស់ប័ណ្ណក៏ដោយ។ ធនាគារមិនទទួលខុសត្រូវ ចំពោះម្ចាស់ប័ណ្ណចំពោះការបាត់បង់ ឬការខូចខាតឡើយ និង/ឬទទួលរងដោយការយឺតយ៉ាវ ផ្នែកបច្ចេកទេស បញ្ហាខាងការបញ្ជូន ដំណើរការមិនប្រក្រតី របស់ម៉ាស៊ីន ATM ឬកាលៈទេសៈមិនអាចដឹងមុនផ្សេងទៀត នៅពេលប្រើម៉ាស៊ីន ATM ឡើយ។

៧.១១ តាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួន ធនាគារអាចកំណត់ថ្លៃបន្ទុកសមហេតុផល ម្តងម្កាល ទាក់ទងនឹងការប្រើប្រាស់ប័ណ្ណ។ ត្រូវជូនដំណឹងជាមុនដល់ម្ចាស់ប័ណ្ណ មុនពេលចុះថ្លៃបន្ទុក ទាំងនេះជាឥណទានពន្ធពីគណនីរបស់ម្ចាស់ប័ណ្ណ។

៧.១២ ធនាគាររក្សាសិទ្ធិក្នុងការបង្ហាញ ដោយរក្សាការសម្ងាត់បំផុត ដល់ស្ថាប័នផ្សេងទៀត ឬតម្រូវដោយច្បាប់ ឬនិយ័តករ តម្រូវម្តងម្កាល នូវរាល់ព័ត៌មានណាមួយទាក់ទងនឹងគណនីរបស់ម្ចាស់ប័ណ្ណ ដែលចាំបាច់ ឬសមស្រប ទាក់ទងនឹងការចូលរួមរបស់ធនាគារនៅក្នុងបណ្តាញផ្ទេរមូលនិធិដោយអេឡិចត្រូនិច។

៧.១៣ ធនាគាររក្សាសិទ្ធិបន្ថែម លុបចោល និង/ឬ ផ្លាស់ប្តូរចំណុចណាមួយនៃ ខ និងលក្ខខណ្ឌនេះ ដោយជូនដំណឹង ឬមិនចាំបាច់ជូនដំណឹងដល់ម្ចាស់ប័ណ្ណ។ ការប្រើប័ណ្ណក្រោយកាលបរិច្ឆេទដែលការផ្លាស់ប្តូរ ខ និងលក្ខខណ្ឌ នេះមានសុពលភាពត្រូវចាត់ទុកថាជាការទទួលយកដោយគ្មានលក្ខខណ្ឌដោយម្ចាស់ប័ណ្ណនូវការផ្លាស់ប្តូរនេះ។ ការប្រើប្រាស់ដោយម្ចាស់ប័ណ្ណ ត្រូវគោរព ខ និងលក្ខខណ្ឌជាធរមាននៅពេលបច្ចុប្បន្ន នៅគ្រប់ពេល។

៧.១៤ កំណត់ត្រាចម្លងការរបស់ធនាគារដែលដំណើរការប្រើប្រាស់ប័ណ្ណ ត្រូវមានភ័ស្តុតាង និងភ្ជាប់កាតព្វកិច្ច សម្រាប់គោលបំណងគ្រប់បែបយ៉ាង។

៧.១៥ ធនាគាររក្សាសិទ្ធិបដិសេធបន្ត ឬជំនួសប័ណ្ណដែលត្រូវបានចេញដោយមិនចាំបាច់បញ្ជាក់អំពីមូលហេតុ និងជូនដំណឹងជាមុនឡើយ។

## ៨. មិនអនុញ្ញាតឲ្យធ្វើការដកប្រាក់ ឬ បង្វិលសាច់ប្រាក់ចេញពីគណនី

៨.១ ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក សូមរក្សាសិទ្ធិធ្វើការស្នើសុំ ត្រួតពិនិត្យ និង ធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អតិថិជន ដើម្បីឆ្លុះបញ្ចាំងទៅនឹងព័ត៌មានចុងក្រោយបំផុតរបស់អតិថិជន។

៨.២ ក្នុងករណីដែលអតិថិជនមិនអាចទាក់ទងបាន ឬខកខានក្នុងការផ្តល់នូវការធ្វើបច្ចុប្បន្នភាព ដូចដែលបានចែងក្នុងប្រការ(១)ខាងលើ ក្នុងរយៈពេល ៣០ថ្ងៃ ធនាគារនឹងផ្តល់ដំណឹងជូនអតិថិជនថា 'មិនអនុញ្ញាតឲ្យធ្វើការដកប្រាក់ ឬ បង្វិលសាច់ប្រាក់ចេញពីគណនី' ចេញពីគណនីរបស់លោកអ្នកទេ ហើយការជូនដំណឹងនេះនឹងធ្វើឡើងតាម រយៈ ការផ្ញើសារ SMS អ៊ីមែល ឬមធ្យោបាយទំនាក់ទំនងផ្សេងៗទៀត ដែលធនាគារនឹងជ្រើសរើស។ សូមអញ្ជើញទៅកាន់សាខារបស់ធនាគារ អ អេច ប៊ី ដែលនៅជិតលោកអ្នកបំផុតដើម្បីធ្វើការផ្ទៀងផ្ទាត់ ។ អតិថិជនយល់ព្រមស្របតាមប្រការខាងលើ ថាគណនីធនាគាររបស់លោកអ្នកអាចត្រូវបានដាក់បញ្ចូលជាប្រភេទគណនី 'មិនអនុញ្ញាតឲ្យធ្វើការដកប្រាក់ ឬ បង្វិលសាច់ប្រាក់ចេញពីគណនី' ដោយមិនមានការប៉ះពាល់ទៅលើធនាគារ ដូចដែលបានចែងក្នុងលក្ខខណ្ឌនៃគណនីដាក់ប្រាក់។

៨.៣ ធនាគារអាចបិទគណនី ឬ អាចដក ឬ អាចផ្អាក ឬ អាចបញ្ចប់សេវាកម្មណាមួយ ឬ ទាំងអស់ដោយមិនចាំបាច់ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់លោកអ្នកជាមុន ដោយធ្វើការអនុលោមទៅតាមគោលការណ៍ណែនាំណាមួយ បុគ្គលណាម្នាក់/សមាគម/អាជ្ញាធរបទបញ្ញត្តិ ឬសិទ្ធិរបស់ធនាគារ អ អេច ប៊ី។ លោកអ្នកទទួលស្គាល់ថាធនាគារមានឆន្ទានុសិទ្ធិមិនអនុវត្តការណែនាំណាមួយ និង/ឬផ្អាកការប្រើប្រាស់គណនី ដូចមានចែងនៅខាងក្រោមនេះ:-

៨.៣.១ ករណីធនាគារមានមន្ទិលលើការស្នើសុំរបស់អតិថិជន; ឬ

៨.៣.២ នៅក្នុងករណីដែលមានវិវាទណាមួយរវាងម្ចាស់គណនីរួម/ហត្ថលេខីដែលមានការអនុញ្ញាត /ភាគីដៃគូ (មិនថាទាក់ទងនឹងភាពជាដៃគូធម្មតា ឬភាពជាដៃគូដែលមានការទទួលខុសត្រូវមានកម្រិត) ឬនាយកក្រុមហ៊ុន; ឬ

៨.៣.៣ ប្រសិនបើធនាគារទទួលបានការណែនាំព័ត៌មានដែលមិនយល់ស្របគ្នា ពីបុគ្គលណាមួយដែលបានរាយបញ្ជីក្រោមចែងក្នុងប្រការ ៣.២ ខាងលើ; ឬ

៨.៣.៤ ប្រសិនបើអ្នកខកខានក្នុងការបង់ថ្លៃសេវា និងការគិតថ្លៃណាមួយដែលកំណត់ដោយ ធនាគារ អ អេច ប៊ី។

## ៩. សេចក្តីប្រកាស

ខ្ញុំបាទ/ នាងខ្ញុំ/ យើងខ្ញុំសូមបញ្ជាក់ថា ខ្ញុំបាទ/ នាងខ្ញុំ យើងខ្ញុំពិតជាបានទទួល អាន និងយល់ច្បាស់ អំពីវិធានរបស់ ធនាគារព្រមទាំង ខ និងលក្ខខណ្ឌ ជាធរមាន ដែលគ្រប់គ្រងលើការបើក និងប្រតិបត្តិការនៃគណនីដែលពាក់ព័ន្ធ។

ហើយយល់ព្រមគោរពតាមវិធាន ព្រមទាំង ខ និងលក្ខខណ្ឌទាំងនេះ។ ធនាគាររក្សា សិទ្ធិក្នុងការបន្ថែម ឬកែប្រែវិធានដែលមានស្រាប់ម្តងម្កាល ដោយមិនចាំបាច់ជូនដំណឹងជាមុន ដល់ខ្ញុំបាទ/ នាងខ្ញុំ/ យើងខ្ញុំឡើយ។

ខ្ញុំបាទ/ នាងខ្ញុំ/ យើងខ្ញុំសូមប្រកាសថា ព័ត៌មានខាងលើគឺជាព័ត៌មានពេញលេញ និងត្រឹមត្រូវ ហើយសន្យាបន្ថែមទៀតថា នឹងផ្តល់ដល់ធនាគារ នូវព័ត៌មាន ឬឯកសារបន្ថែមដែលទាមទារម្តងម្កាលនៅពេលក្រោយឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបានតាមសំណើរបស់ធនាគារ។

ហើយខ្ញុំបាទ/ នាងខ្ញុំ/ យើងខ្ញុំមានសមត្ថភាពពេញលេញតាមផ្លូវច្បាប់ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។